Government of **Western Australia**
**North Metropolitan Health Service**

BreastScreen WA
's only accredited screening service

# ខ្លឹមសារស្តីអំពីការថតឆ្លុះមើលដោះដោយប្រើកាំរស្មីអិក្ស

## សូមស្វាគមន៍ដែលបានអញ្ជើញមកមន្ទីរថតឆ្លុះមើលដោះ BreastScreen WA ...

| |
|---|
| សូមអានព័ត៌មានដ៏សំខាន់នេះអំពីថតឆ្លុះមើលដោះដោយប្រើកាំរស្មីអិក្ស ហើយបំពេញហ្វ៊មអនុញ្ញាតយល់ព្រមដែលមានភ្ជាប់មកជាមួយនេះ មុនការថតឆ្លុះមើលដោះរបស់អ្នក។ ប្រសិនបើអ្នកមានសំនួរណាមួយ បុគ្គលិកធ្វើការនៅតាមក្រុមថតឆ្លុះមើលដោះអាចជួយអ្នកបាន។ សូមកត់ចំណាំថាអ្នកអាចបញ្ឈប់ដំណើរការថតឆ្លុះមើលដោះនេះនៅពេលណាមួយក៏បាន។ |

**អំពីកម្មវិធីការថតឆ្លុះមើលដោះដោយប្រើកាំរស្មីអិក្ស**

គោលដៅនៃកម្មវិធីថតឆ្លុះមើលដោះដោយប្រើកាំរស្មីអិក្ស គឺដើម្បីកាត់បន្ថយនូវការស្លាប់ដែលបណ្តាលពីជម្ងឺមហារីកដោះ។ ការថតឆ្លុះមើលដោះ (ការថតឆ្លុះមើលដោះដោយប្រើកាំរស្មីអ៊ិក្ស) គឺជាវិធីដ៏ល្អបំផុតដែលយើងមានក្នុងពេលបច្ចុប្បន្ននេះ ដើម្បីតាមដានរកមើលជម្ងឺមហារីកដោះដែលវានៅតូចពេកពុំអាចនឹងស្ទាបដឹង។ ការធ្វើរោគវិនិច្ឆ័យមហារីកដោះបានល្អមុនពេល នឹងផ្តល់នូវឱកាសបានកាន់តែប្រសើរដើម្បីព្យាបាលប្រកបដោយជោគជ័យ។

ការយកចិត្តទុកដាក់ខ្លាំងនៃកម្មវិធី BreastScreen WA Program គឺឋិតនៅលើការតាមដានរកមើលជម្ងឺមហារីកដោះឲ្យបានទាន់ពេល។ ការផ្លាស់ប្តូរទាំងឡាយណាដែលឃើញមាននៅលើការថតឆ្លុះមើលដោះរបស់អ្នក ដែលមិនបានចាត់ទុកថាជាសញ្ញានៃរោគមហារីដោះ មិនបានត្រូវគេរាយការណ៍ទេ។

ភ័ស្តុតាងផ្នែកវិជ្ជសាស្ត្របច្ចុប្បន្នបង្ហាញថាការថតឆ្លុះមើលដោះ គឺមានប្រយោជន៍ជាទីបំផុតសំរាប់ស្ត្រីដែលមានអាយុ៥០-៦៩ឆ្នាំ។ លទ្ធភាពនៃការកើតមានជម្ងឺមហារីកដោះរបស់អ្នក គឺកើនទៅតាមអាយុ។ ស្ទើរតែ៧០ភាគរយនៃជម្ងឺមហារីកដោះ កើតមានឡើងនៅក្នុងចំណោមស្ត្រីដែលមានអាយុ៥០ឆ្នាំ ឬចាស់ជាង។ ការថតឆ្លុះមើលដោះជាទៀងទាត់ អាចកាត់បន្ថយនូវការស្លាប់ប្រហែលជា៣០ភាគរយនៅក្នុងចំណោមស្ត្រីទាំងនេះ។ ផលប្រយោជន៍នៃការថតឆ្លុះមើលដោះ មានផលប្រយោជន៍តិចជាងសំរាប់ស្ត្រីដែលមានអាយុនៅក្រោមអាយុ៥០ឆ្នាំ។

**តើគេថតឆ្លុះមើលដោះដោយបែបយ៉ាងណា?**

**អ្នកនឹងត្រូវគេស្នើសុំឲ្យដោះសម្លៀកបំពាក់ទុកឲ្យនៅត្រឹមចង្កេះ ហើយផ្តល់អាវរ៉ូបឲ្យពាក់។ អ្នកថតស្រីម្នាក់ដែលមានការហ្វឹកហ្វឺនជាក់លាក់នឹងថតឆ្លុះមើលដោះរបស់អ្នក។**

ក្នុងកាលដែលការថតដោះកំពុងប្រព្រឹត្តទៅ នោះគេនឹងសង្កត់ដោះរបស់អ្នកចំនួនពីរបីវិនាទី ដើម្បីឲ្យបានទទួលនូវរូបភាពដែលច្បាស់។ ការនេះអាចធ្វើឲ្យអ្នកមិនស្រួលបន្តិច។

ជាធម្មតាគេត្រូវការថតយករូបភាពដោះចំនួនពីរផ្ទាំង ចេញពីដោះម្ខាងៗ ក៏ប៉ុន្តែពេលខ្លះគេត្រូវការចំនួនច្រើនជាងនេះ ប្រសិនបើចាំបាច់។

**តើនរណានឹងពិនិត្យមើលហ្វីលថតដោះ?**

**លទ្ធផលនៃការថតឆ្លុះមើលដោះរបស់អ្នក នឹងផ្អែកទៅលើការព្រមព្រៀងរវាងយ៉ាងហោចណាស់វេជ្ជបណ្ឌិតឯកទេស (អ្នកវិទ្យុព្យាបាល) ពីររូបដែលមានបទពិសោធន៍យ៉ាងស្ទាត់ជំនាញនៅក្នុងការពិនិត្យមើលហ្វីលថតដោះ។ គ្រប់ទាំងហ្វីលថតដោះត្រូវបានគេពិនិត្យមើលដាច់ដោយឡែកពីគ្នា។ ជួនកាល ប្រសិនបើអ្នកវិទ្យុព្យាបាលពីរនាក់ដំបូងមិនយល់ស្របនឹងគ្នាទេ អ្នកវិទ្យុព្យាបាលទីបីនឹងពិនិត្យមើលហ្វីលថតដោះរបស់អ្នក។**

**ចុះប្រសិនបើខ្ញុំត្រូវការថតឆ្លុះមើលដោះម្តងទៀត?**

យូរៗម្តង អ្នកវិទ្យុព្យាបាលនឹងស្នើសុំឲ្យមានការថតឆ្លុះមើលដោះម្តងទៀត ប្រសិនបើរូបភាពដែលបានថតហើយមើលមិនសូវច្បាស់។ ប្រសិនបើករណីនេះវាចាំបាច់ អ្នកនឹងបានទទួលការហៅតាមទូរស័ព្ទ ឬតាមសំបុត្រដើម្បីស្នើសុំឲ្យអ្នកមកធ្វើម្តងទៀត។ ការថតឆ្លុះមើលដោះទាំងនេះនឹងត្រូវធ្វើនៅតាមមន្ទីរថតឆ្លុះមើលដោះ។

### ការផ្តល់ដំណឹងអំពីលទ្ធផល

**ស្ត្រីភាគច្រើននឹងបានទទួលដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល១៤ថ្ងៃ ថាដោះរបស់គេនៅល្អទាំងអស់។ វាមិនមែនជាការប្លែកខុសធម្មតាទេ សំរាប់ស្ត្រីខ្លះដែលត្រូវគេហៅឲ្យត្រឡប់មកវិញដើម្បីធ្វើតេស្តបន្ថែម។ ប្រសិនបើចាំបាច់ គិលានុប្បដ្ឋាកស្នង់ប៉ាន់ដោះមកពី BreastScreen WA នឹងទូរស័ព្ទពិភាក្សារឿងនេះជាមួយអ្នក។ ភាគច្រើន តេស្តទាំងនេះនឹងមិនបង្ហាញឲ្យឃើញបញ្ហាណាមួយដែលត្រូវការស៊ើបអង្កេតតទៅទៀតទេ។**

ស្ត្រីទាំងឡាយណាដែលត្រូវគេថតឆ្លុះមើលនៅតាមតំបន់ជាយក្រុង នឹងត្រូវគេធ្វើការណាត់ជួបនៅតាមមជ្ឈមណ្ឌលស្នង់ប៉ាន់កម្មវិធី ជាកន្លែងដែលតម្រូវឲ្យមានការពិនិត្យមើលហ្វីលថតដោះបន្ថែម ឬប្រសិនបើត្រូវការ នោះគេនឹងរៀបចំមានមានការធ្វើតេស្តផ្សេងទៀត។

ចំពោះស្ត្រីទាំងឡាយណាដែលត្រូវគេថតឆ្លុះមើលនៅតាមក្រុមចល័តជនបទ ការពិនិត្យមើលហ្វីលថតដោះបន្ថែមទាំងនេះនឹងត្រូវគេធ្វើឡើងនៅតាមរថយន្តចល័ត សំរាប់ពេលសមស្របរបស់គេ។

**សូមកត់សំគាល់:** BreastScreen WA នឹងរក្សាទុកហ្វីលថតដោះដើម្បីយកទៅប្រៀបធៀបជាមួយនឹងហ្វីលថតដោះទៅអនាគត។

### តើការថតឆ្លុះមើលដោះគួរឲ្យទុកចិត្តបានយ៉ាងណាដែរ?

**ការថតឆ្លុះមើលដោះអាចចង្អុលបង្ហាញឲ្យឃើញរហូតដល់ទៅ៩០ភាគរយនៃជម្ងឺមហារីកដោះ។ មានជម្ងឺមហារីកខ្លះដែលមិនគេអាចមើលឃើញតាមរយៈការថតឆ្លុះមើលដោះឡើយ។ ស្ត្រីវ័យក្មេង ឬស្ត្រីដែលប្រើការព្យាបាលដោយដាក់ជាតិអ័រម៉ូនជំនួសវិញ (Hormone Replacement Therapy) អាចមានជាលិកាដោះណែនច្រើនជាងស្ត្រីដែលមានវ័យចាស់ជាង ហើយការនេះអាចធ្វើឲ្យមានការលំបាកច្រើនជាង ក្នុងការរកឲ្យឃើញនូវជម្ងឺមហារីកពីការថតឆ្លុះមើលដោះ។ អាស្រ័យហេតុនេះ ស្ត្រីដែលមានវ័យក្មេងជាងតម្រូវឲ្យមានការស៊ើបអង្កេតកាន់ច្រើនជាង មានរួមទាំងការកាត់សាច់ដោះយកមកពិនិត្យមើល ដោយព្រោះមានការលំបាកក្នុងការបដិសេធនូវជម្ងឺមហារីក នៅលើមូលដ្ឋាននៃការថតឆ្លុះមើលដោះ។**

ស្រដៀងគ្នានេះដែរ ការថតឆ្លុះមើលដោះអាចមើលទៅគួរឲ្យខ្វល់ខ្វាយពីដំបូង ក៏ប៉ុន្តែការស៊ើបអង្កេតបន្ថែមបង្ហាញថាគ្មានបញ្ហាធ្ងន់ធ្ងរសោះឡើយ។

ការថតឆ្លុះមើលដោះមិនអាចការពារជម្ងឺមហារីកដោះបានឡើយ ក៏ប៉ុន្តែការតាមដានរកឃើញបានទាន់ពេលជួយធានាអះអាងនឹងផ្តល់នូវឱកាសបានកាន់តែប្រសើរដើម្បីព្យាបាលប្រកបដោយជោគជ័យ។

### តើការថតឆ្លុះមើលដោះអាចធ្វើឲ្យមានគ្រោះថ្នាក់ណាមួយឬទេ?

**ជួនកាលការសង្កត់ដែលគេប្រើដើម្បីថតឆ្លុះមើលដោះអាចបណ្តាលឲ្យមានការទន់ជ្រាយដោះ ឬជាំខ្លះៗបណ្តោះអាសន្ន។ ការនេះមិនបណ្តាលឲ្យមានគ្រោះថ្នាក់យូរអង្វែងណាមួយទៅដល់ជាលិកាដោះទេ។**

ការថតឆ្លុះមើលដោះនីមួយៗ ប្រើចំហាយវិទ្យុសកម្មដែលមានកំរិតយ៉ាងទាប។ ភ័ស្តុតាងបច្ចុប្បន្នបង្ហាញឲ្យឃើញថាមានគ្រោះថ្នាក់បន្តិចបន្តួចណាស់ទាក់ទិននឹងការប៉ះត្រូវចំហាយវិទ្យុសកម្មនេះ។ ផលប្រយោជន៍ពីការថតឆ្លុះមើលដោះ មានផលប្រយោជន៍ច្រើនជាងគ្រោះថ្នាក់នេះ។ ពុំមានការណែនាំចំពោះស្ត្រីទាំងឡាយណាដែលសង្ស័យថាខ្លួនមានផ្ទៃពោះ ឲ្យទទួលយកការថតឆ្លុះមើលដោះឡើយ។ ប្រសិនបើមានលទ្ធភាពថាអ្នកអាចមានផ្ទៃពោះ សូមប្រាប់អ្នកទទួលភ្ញៀវ ឬអ្នកថតឆ្លុះមើលដោះឲ្យគេបានដឹង។

**ពុំមានការណែនាំចំពោះស្ត្រីទាំងឡាយណាដែលសង្ស័យថាខ្លួនមានផ្ទៃពោះ ឲ្យទទួលយកការថតឆ្លុះមើលដោះឡើយ។ ប្រសិនបើមានលទ្ធភាពថាអ្នកអាចមានផ្ទៃពោះ សូមប្រាប់អ្នកទទួលភ្ញៀវ ឬអ្នកថតឆ្លុះមើលដោះឲ្យគេបានដឹង។**

### ចុះបើខ្ញុំមានដុំពកនៅដោះ ឬមានបញ្ហាដោះក្នុងពេលឥឡូវនេះ?

ប្រសិនបើអ្នកសំគាល់ដឹងថាមានដុំពកនៅក្នុងដោះរបស់អ្នក ហូរចេញវត្ថុពីចុងដោះ ឬមានដំណើរផ្លាស់ប្តូរដទៃទៀតនៅក្នុងដោះរបស់អ្នក សូមប្រាប់អ្នកថតឆ្លុះមើលដោះរបស់អ្នក មុននឹងអ្នកទទួលការថតឆ្លុះមើលដោះ។ វាក៏ជាការសំខាន់ដែលអ្នកត្រូវជួបជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីរោគសញ្ញាទាំងនេះ ទោះបីជាហ្វីលថតដោះបង្ហាញឲ្យឃើញធម្មតាក្តី។

### ហេតុអ្វីបានជាខ្ញុំត្រូវផ្តល់ព័ត៌មានរបស់វេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (GP) របស់ខ្ញុំទៅឲ្យអ្នក?

ដើម្បីផ្តល់ជូនអ្នកនូវការមើលថែដ៏ល្អបំផុត GP របស់អ្នកត្រូវតែបានទទួលនូវព័ត៌មានអំពីគ្រប់ទាំងការមើលថែសុខភាពរបស់អ្នក។ យើងត្រូវការបញ្ជូនលទ្ធផលនៃការថតឆ្លុះមើលដោះរបស់អ្នកទៅឲ្យវេជបណ្ឌិតរបស់អ្នក។ នៅចន្លោះរវាងការថតឆ្លុះមើលដោះ វាជាការសំខាន់ដែលអ្នកត្រូវពិនិត្យមើលដោះរបស់អ្នកឲ្យបានទៀងទាត់ ហើយថាអ្នកត្រូវរាយការណ៍អំពីការផ្លាស់ប្តូរណាមួយឲ្យបានភ្លាមៗទៅវេជ្ជបណ្ឌិតរបស់អ្នក។ យើងសូមណែនាំដល់ដែលគួរឲ្យវេជ្ជបណ្ឌិរបស់អ្នក ឆែកមើលដោះអ្នកឲ្យបានទៀងទាត់។